00629912

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

A4 10/2/3

អង្គបុរេជំនុំជម្រះ
Pre-Trial Chamber
Chambre Préliminaire

សំណុំរឿងព្រហ្មទណ្ឌលេខៈ ០០២/១៩-០៩-២០០៧/អវតក/កសចស(អបជ១៤៧)

ចំពោះមុខ៖
ចៅក្រម ប្រាក់ គឹមសាន, ប្រធាន
ចៅក្រម Rowan DOWNING
ចៅក្រម នីយ ធុល
ចៅក្រម Catherine MARCHI-UHEL
ចៅក្រម ហួត វុទ្ធី

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 07 / 12 / 2010
ម៉ោង (Time/Heure): 10:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Ratanak

កាលបរិច្ឆេទ៖ ថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១០

---

**សាធារណៈ**

**សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ដោយផ្អែកលើសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរ**

---

**មេធាវីនៃភាគីដើមបណ្តឹងរដ្ឋប្បវេណី**

ស៊ិន សុវ៉ន
ហុង គឹមសួន
គង់ ពិសី
SILKE Studzinsky
យុង ផានិត
LYMA Nguyen

**មេធាវីនៃភាគីដើមបណ្តឹងរដ្ឋប្បវេណី**

ឡោ ជុនធី
គឹម ម៉េងឃី
ម៉ុច សុវណ្ណារី
Martine JACQUIN
Philippe CANONNE
Elizabeth RABESANDRATANA

DESFORGES Laure
DURAND Isabelle
GAUTRY Francoise
MARTINEAU Christine
Pascal AUBOIN
Ferdinand Djammen-Nzepa
Emmanuel ALTIT

**សហព្រះរាជអាជ្ញា**

ជា លាង
Andrew CAYLEY

**សហមេធាវីការពារក្តី**

អាង ឧត្តម
Michael G. KARNAVAS
ផាត់ ពៅស៊ាង
Diana ELLIS
សុន អរុណ
Michiel PESTMAN
Victor KOPPE
សា សុវ៉ាន
Jacques VERGES

Mahdev MOHAN
Olivier BAHOUGNE
DELAHAIE Annie
Fabienne TRUSSES-NAPROUS
BAUDOUIN Patrick
GUIRAUD Marie
Emmanuel JACOMY
Julien RIVET
Barnabe NEKUIE
Nicole DUMAS
Daniel LOSQ

ជេត វណ្ណលី

វ៉ែន ពៅ

ទី ស្រ៊ុនណា

ពេជ អង្គ

**អង្គបុរេជំនុំជម្រះ** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (“អវតក”) បានឃើញ “បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងចម្លើយរបស់សហចៅក្រមស៊ើបអង្កេត ទៅនឹងសំណើស្តីពីការរក្សាការសម្ងាត់ សមភាព និង យុត្តិធម៌” (“បណ្តឹងឧទ្ធរណ៍”) ដែលសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី បានដាក់កាលពីថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១០។

១. ដោយហេតុថាបណ្តឹងឧទ្ធរណ៍ ដែលសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានដាក់នេះពាក់ព័ន្ធទៅនឹងលក្ខខណ្ឌការងាររបស់ការិយាល័យរដ្ឋបាល អង្គបុរេជំនុំជម្រះបានអញ្ជើញការិយាល័យរដ្ឋបាល កាលពីថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១០ ឱ្យដាក់ចម្លើយតបទៅ នឹងបណ្តឹងឧទ្ធរណ៍នេះ[១]។

២. នៅថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១០ ការិយាល័យរដ្ឋបាលបានដាក់ “ចម្លើយរបស់ខ្លួនចំពោះ ‘សំណើរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីស្តីពីការរក្សាការសម្ងាត់ សមភាព និងយុត្តិធម៌ ដែលត្រូវបានដាក់នៅការិយាល័យសហចៅក្រមស៊ើបអង្កេតកាលពីថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១០’ និងចំពោះ ‘បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងចម្លើយរបស់សហចៅក្រមស៊ើបអង្កេតលើសំណើ ស្តីពីការរក្សាការសម្ងាត់ សមភាព និង យុត្តិធម៌ ដែលត្រូវបានដាក់នៅថ្ងៃទី១២ ខែតុលា ឆ្នាំ២០១០”[២]។

៣. អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី និង ការិយាល័យរដ្ឋបាល មិនបានស្នើសុំឱ្យមានសវនាការជាសាធារណៈនោះទេ។

៤. វិធាន ៧៧(៣)(ខ) នៃវិធានផ្ទៃក្នុង (វិសោធនកម្មលើកទី៥) ចែងថា៖

> បន្ទាប់ពីបានពិចារណាលើការយល់ឃើញរបស់ភាគី អង្គបុរេជំនុំជម្រះអាចសម្រេចលើបណ្តឹងឧទ្ធរណ៍ ឬពាក្យសុំ ដោយផ្អែកតែលើមូលដ្ឋាននៃសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សររបស់ភាគីតែប៉ុណ្ណោះ។

---

[១] “បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងចម្លើយរបស់សហចៅក្រមស៊ើបអង្កេតទៅនឹងសំណើលើការរក្សាការសម្ងាត់ សមភាព និងយុត្តិធម៌” ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១០ ឯកសារលេខ A410/2/1។

[២] “ចម្លើយចំពោះ ‘សំណើរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីស្តីពីការរក្សាការសម្ងាត់ សមភាព និង យុត្តិធម៌ ដែលដាក់ទៅការិយាល័យសហចៅក្រមស៊ើបអង្កេតនៅថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១០’ និង ‘បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងចម្លើយរបស់សហចៅក្រមស៊ើបអង្កេតចំពោះសំណើស្តីពីការរក្សាការសម្ងាត់ សមភាព និង យុត្តិធម៌ ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០១០’” ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១០ ឯកសារលេខ A410/2/2។

៥. អង្គបុរេជំនុំជម្រះយល់ឃើញថា មិនមានការចាំបាច់ណាមួយ ដែលត្រូវឱ្យបើកសវនការជាសាធារណៈលើបណ្តឹងឧទ្ធរណ៍នេះទេ ដោយហេតុថាបណ្តឹងឧទ្ធរណ៍នេះអាចត្រូវបានសម្រេចបានដោយផ្អែកទៅលើសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរ។

៦. អនុលោមតាមមាត្រា៨(៤) នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារនៅចំពោះមុខអ.វ.ត.ក សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីអាចដាក់ចម្លើយតបរបស់ខ្លួនជាលាយលក្ខណ៍អក្សរបាន។

៧. លើសពីនេះទៀត ដោយពិចារណាឃើញថាការិយាល័យរដ្ឋបាលបានដាក់សារណារបស់ ខ្លួនដែលពាក់ព័ន្ធទៅនឹងការប្រព្រឹត្តរបស់សហមេធាវីជាក់លាក់មួយចំនួន ដូចមានរៀបរាប់ឈ្មោះនៅក្នុងកថាខណ្ឌ៩, កថាខណ្ឌ១៤, កថាខណ្ឌ២៥ និងកថាខណ្ឌ២៦ នៃចម្លើយរបស់ការិយាល័យរដ្ឋបាល សហមេធាវីដែលមានឈ្មោះទាំងនោះ ត្រូវបានអនុញ្ញាតឱ្យដាក់ចម្លើយតបបន្ថែមទៅតាមលទ្ធភាពផ្ទាល់ខ្លួនរបស់ពួកគាត់ ប្រសិនបើខ្លួនមានបំណងដាក់ចម្លើយតប។

**ហេតុដូច្នេះ អង្គបុរេជំនុំជម្រះ÷**

(១) **សម្រេច** លើបណ្តឹងឧទ្ធរណ៍នេះ ដោយផ្អែកលើសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរ។

(២) **អញ្ជើញ** សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវីដែលមានឈ្មោះនៅក្នុងកថាខណ្ឌ៩, កថាខណ្ឌ១៤, កថាខណ្ឌ២៥ និងកថាខណ្ឌ២៦ នៃចម្លើយរបស់ការិយាល័យរដ្ឋបាល ឱ្យដាក់ចម្លើយតបទៅតាមលទ្ធភាពផ្ទាល់ខ្លួន តាមឱសានវាទដូចបានកំណត់នៅ ក្នុងមាត្រា៨.៤ នៃសេចក្តីណែនាំអនុវត្ត អវតក/០១/២០០៧/វិសោធនកម្មទី៥។

ភ្នំពេញ ថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១០

ប្រធានអង្គបុរេជំនុំជម្រះ

PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

ប្រាក់ គឹមសាន